# សុវណ្ណកក្កដកជាតក



*ព្រះសាស្តា កាលស្តេចគង់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធការបរិច្ចាគជីវិត របស់ព្រះអានន្ទត្ថេរ ដើម្បីប្រយោជន៍ដល់ព្រះអង្គ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **សិង្គីមិគោ** *ដូច្នេះជាដើម ។*

*រឿងរ៉ាវ (ពីដំបូង) រហូតមកដល់ការប្រកបដោយនាយខ្មាន់ធ្នូ បានពោលហើយក្នុង* ***ខណ្ឌហាលជាតក**, ការលែងដំរីធនបាល បានពោលហើយក្នុង**ចូឡហំសជាតក** និង**មហា-ហំសជាតក** ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយញាំងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ ព្រះអានន្ទត្ថេរជា**ធម្មភណ្ឌាគារិកៈ** ជាអ្នកដល់**សេក្ខបដិសម្ភិទា** កាលដំរីធនបាលរត់មកហើយ លោកបានបរិច្ចាគជីវិតដល់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វី ? កាលភិក្ខុទាំងឡាយទូលថា ដោយរឿងឈ្មោះនេះ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិន*

*មែនតែក្នុងឥឡូវនេះទេ សូម្បីក្នុងកាលមុន អានន្ទក៏បានបរិច្ចាគជីវិតដល់តថាគតដែរ ដូច្នេះហើយ ទ្រង់ទើបនាំអតីតនិទានមកថា*

*ក្នុងអតីតកាល មានស្រុកព្រាហ្មណ៍មួយឈ្មោះ **សាលិន្ទិយៈ** នៅទិសខាងកើតក្រុងរាជគ្រឹះ ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងត្រកូល**កស្សកព្រាហ្មណ៍** ក្នុងស្រុកសាលិន្ទិយៈនោះ កាលចម្រើនវ័យធំហើយ រៀបចំទុកដាក់ទ្រព្យ ហើយឲ្យគេធ្វើស្រែដោយដីប្រមាណ **១០០០ ករីសៈ** ( ១ ករីសៈ = ១៤ ម៉ែត្រ > ១០០០ ករីសៈ = ១៤០០០ម៉ែត្រ ) ក្នុងគាមខេត្តមួយ ដែលនៅទិសឦសាននៃស្រុកនោះ ។ ថ្ងៃមួយ ព្រះពោធិសត្វទៅស្រែជាមួយនឹងមនុស្សទាំងឡាយ ហើយបញ្ជាកម្មករថា អ្នកទាំងឡាយចូរភ្ជួរ ដូច្នេះហើយ លោកចូលទៅជិតអន្ទង់ដ៏ធំដែលនៅខាងចុងស្រែ ដើម្បីលាងមុខ ។ ក្នុងអន្ទង់នោះ មានក្ដាមពណ៌មាសមួយ ដែលមានរូបដ៏ស្អាត គួរជាទីជ្រះថ្លា អាស្រ័យនៅ ។ ព្រះពោធិសត្វទំពាឈើស្ទន់ហើយទម្លាក់ឈើស្ទន់ចូលទៅក្នុងអន្ទង់នោះ ។ ក្នុងវេលាដែលព្រះពោធិសត្វជម្រះមុខ ក្ដាមមកកាន់សម្នាក់ព្រះពោធិសត្វ ។ លំដាប់នោះ ព្រះពោធិសត្វចាប់លើកក្ដាមនោះ ដាក់ឲ្យដេកក្នុងចន្លោះឧត្តរិសាដករបស់ខ្លួន ហើយធ្វើកិច្ចការក្នុងស្រែ កាលត្រឡប់ទៅ ទើបដាក់ក្ដាមទៅក្នុងអន្ទង់នោះវិញ រួចទើបលោកទៅផ្ទះ ។ ចាប់ពីពេលនោះមក កាលព្រះពោធិសត្វមកស្រែ តែងតែទៅកាន់អន្ទង់នោះជាដំបូង ហើយចាប់លើកក្ដាមដាក់ឲ្យដេកក្នុងឧត្តរិសាដក រួចទើបឲ្យកិច្ចការប្រព្រឹត្តទៅ ។ ព្រោះហេតុនោះ សេចក្ដីស្និទ្ធស្នាលនូវគ្នានឹងគ្នារបស់ព្រះពោធិសត្វនិងក្ដាមនោះ ក្លាយជាមេត្រីភាពដ៏មាំ ។*

*ព្រះពោធិសត្វមកកាន់ស្រែជាប់ជានិច្ច ក៏ឯប្រសាទទាំង ៥ ក្នុងភ្នែករបស់ព្រះពោធិសត្វប្រាកដដូចមណ្ឌល ៣ ដ៏បរិសុទ្ធ ។ នៅខាងចុងស្រែរបស់ព្រះពោធិសត្វនោះ មាក**កាកី** ( ក្អែកញី ) ដែលនៅក្នុងសំបុក នៅលើដើមត្នោត បានឃើញភ្នែក ( របស់ព្រះពោធិសត្វ ) ហើយ ក៏មានសេចក្ដីប្រាថ្នាចង់បរិភោគ ទើបពោលនឹងក្អែកឈ្មោលថា បពិត្រស្វាមី ចំណង់ដ៏ប្លែកកើតឡើងដល់អូន ។ ក្អែកឈ្មោលសួរថា ចំណង់ប្លែកដូចម្ដេច ? ក្អែកញីពោលថា អូនចង់បរិភោគភ្នែករបស់ព្រាហ្មណ៍នោះ ។ ក្អែកឈ្មោលពោលថា ចណង់ប្លែកដ៏លំបាកកើត*

ឡើងដល់អូន តើអ្នកណានឹងអាចនាំភ្នែកនោះបាន ។ ក្អែកញីពោលថា បងមិនអាចឬ ? ប៉ុន្តែអូនដឹងឧបាយមួយ នៅក្នុងទីមិនឆ្ងាយពីដើមត្នោតនេះ មានដំបូកមួយ ក្នុងដំបូកនោះមានពស់វែកក្របីមួយនៅ ។ បងចូរទៅបម្រើពស់នោះ ពស់នោះចឹកសម្លាប់ព្រាហ្មណ៍ ហើយបងឆ្កៀលភ្នែករបស់ព្រាហ្មណ៍ រួចនាំមក ។ ក្អែកឈ្មោលទទួលថា ល្អ ដូច្នេះហើយ ចាប់ពីពេលនោះមក ក៏ចូលទៅបម្រើពស់ ។ ក្នុងកាលដែលសន្ទូងរបស់ព្រះពោធិសត្វផើម ក្តាមនោះក៏ធំ ។ ថ្ងៃមួយ ពស់ពោលនឹងក្អែកថា នែសម្លាញ់ លោកមកបម្រើខ្ញុំជាប់ជានិច្ច តើខ្ញុំនឹងធ្វើអ្វីដល់លោក ។ ក្អែកពោលថា បពិត្រលោកម្ចាស់អើយ ចំណង់ចម្ងែកកើតឡើងដល់ទាសីរបស់លោកម្ចាស់ ខ្ញុំមកបម្រើលោក ដោយគិតថា នឹងបានភ្នែករបស់ព្រាហ្មណ៍នោះ ដោយអានុភាពរបស់លោក ។ ពស់ពោលថា មិនជាធ្ងន់ទេ អ្នកនឹងបាន ដូច្នេះហើយ ពស់ញុំាងក្អែកឲ្យបានធូរចិត្ត ។ ក្នុងថ្ងៃស្អែក ក្នុងវេលាដែលព្រាហ្មណ៍មកកាន់ផ្លូវ ពស់បិទបាំងខ្លួនដោយស្មៅ អាស្រ័យនឹងភ្លឺស្រែ ដេកចាំមើលដំណើរមករបស់ព្រាហ្មណ៍នោះ ។

ព្រះពោធិសត្វកាលមក លោកចុះទៅក្នុងអន្ទង់ជាដំបូង ជម្រះមុខ ញុំាងសេចក្តីស្នេហាឲ្យតាំងឡើង ចាប់ត្រកងក្តាមមាស ដាក់ឲ្យដេកក្នុងចន្លោះឧត្តរិសាដក ហើយចូលទៅស្រែ ។ ពស់កាលឃើញព្រាហ្មណ៍មក ក៏ស្ទុះទៅដោយរហ័ស ចឹកស្មងជើង ឲ្យព្រាហ្មណ៍ដួលចុះ រួចទើបវារសំដៅទៅកាន់ដំបូក ។ ការដួលរបស់ព្រាហ្មណ៍ ការលោតចេញពីចន្លោះសាដក និងការមករបស់ក្អែក ហើយទំលើទ្រូងរបស់ព្រាហ្មណ៍ បានប្រព្រឹត្តទៅព្រមគ្នា មិនមុនមិនក្រោយ ។ ក្អែកចុះទំហើយ ប្រុងនឹងប្រហារភ្នែកដោយចំពុះ ។ ក្តាមគិតថា ភ័យកើតឡើងដល់សម្លាញ់របស់យើងដោយអាស្រ័យក្អែកនេះ បើយើងចាប់ក្អែកនេះ ពស់នឹងត្រឡប់មកដូច្នេះហើយ ក៏ចាប់កក្អែកដោយតង្កៀប ហាក់ដូចជាកៀបដោយដង្កាប់ ញុំាងក្អែកឲ្យលំបាកហើយធ្វើការបន្ធូរតិចៗ ។ ក្អែកកាលនឹងហៅពស់ថា នែសម្លាញ់ អ្នកបោះបង់ខ្ញុំហើយវារទៅដើម្បីអ្វី ក្តាមនេះបៀតបៀនខ្ញុំខ្លាំងណាស់ ខ្ញុំមិនទាន់ស្លាប់ដរាបណា អ្នកចូរមកដរាបនោះ ដូច្នេះទើបពោលគាថាទី ១ ថា

**សិង្គិមិគោ អាយតចក្ខុនេត្តោ, អដ្ឋិត្តចោ វារិសយោ អលោមោ;**
**តេនាភិភូតោ កបណំ រុទាមិ, ហរេ សខា កិស្ស នុ មំ ជហាសិ។**

*ម្រឹគមានពណ៌ដូចមាស (ក្ដាម) មានភ្នែកលៀន មានស្បែកដូចឆ្អឹង អាស្រ័យនៅក្នុងទឹក ជាសត្វមិនមានរោម ខ្ញុំត្រូវក្ដាមនោះគ្របសង្កត់ ទើបយំ កំព្រា (តែម្នាក់ឯង) ម្នាលសម្លាញ់អើយ ហេតុអ្វី ទើបអ្នកបោះបង់ខ្ញុំចោល។*

*បណ្ដាបទទាំងនោះ បទថា* **សិង្គិមិគោ** *សេចក្ដីថា ក្ដាម លោកហៅថា* **សិង្គីមិគៈ** *ព្រោះមានពណ៌ដូច***មាសសិង្គី** *និងព្រោះមានស្នែង ពោលគឺតង្កៀប។ បទថា* **អាយតចក្ខុនេត្តោ** *សេចក្ដីថា ដល់ព្រមដោយនេត្រា ពោលគឺភ្នែកវែង។ ឆ្អឹងនោះឯង ជាស្បែក របស់សត្វនោះ ព្រោះហេតុនោះ សត្វនោះ ទើបឈ្មោះថា* **អដ្ឋិត្តចៈ** *(សត្វមានស្បែកជាឆ្អឹង)។ បទថា* **ហរេ សខា** *សេចក្ដីថា ត្រឹមតែជាពាក្យហៅ លោកអធិប្បាយថា នែសម្លាញ់ដ៏ចម្រើន។*

*ពស់ស្ដាប់ពាក្យនោះហើយ បើកពពារដ៏ធំ កាលនឹងឲ្យក្អែកធូរចិត្ត ទើបមក។ ព្រះសាស្ដា កាលនឹងបំភ្លឺសេចក្ដីនោះ ក៏ត្រាស់អភិសម្ពុទ្ធគាថាទី ២ ថា*

**សោ បស្សសេន្តោ មហតា ផណេន, កុជង្គមោ កក្កដមជ្ឈុបេត្តោ;**
**សខា សខារំ បរិតាយមានោ, កុជង្គមំ កក្កដកោ គហេសិ។**

*ពស់នោះ កាលជួយ (ក្អែកនោះ) បើកពពាដ៏ធំ លូនចូលទៅជិតក្ដាម យកអាសាការពារសម្លាញ់ដ៏ស្និទ្ធស្នាល ក្ដាមក៏ចាប់ពស់ទៀត។*

*បណ្ដាបទទាំងនោះ បទថា* **កក្កដមជ្ឈុបេត្តោ** *សេចក្ដីថា ដល់ទីជិតក្ដាម។ បទថា* **សខា សខារំ** *បានដល់ សម្លាញ់ចូលទៅរកសម្លាញ់។ បាឋៈថា* **សកំ សខារំ** *ដូច្នេះក៏មានអធិប្បាយថា ចូលទៅរកសម្លាញ់របស់ខ្លួន។ បទថា* **បរិតាយមានោ** *សេចក្ដីថា កាលរក្សា។ បទថា* **គហេសិ** *សេចក្ដីថា ចាប់យ៉ាងមាំត្រង់ក ដោយតង្កៀបទាំង ២។*

*លំដាប់នោះ ក្តាមញ៉ាំងក្អែកឲ្យលំបាកហើយ ទើបធ្វើការបន្ទូរបន្ថិច ។ ចំណែកពស់គិតថា ឈ្មោះថា ក្តាម រមែងមិនស៊ីក្អែក និងមិនស៊ីសាច់ពស់ ព្រោះហេតុអ្វី ក្តាមនេះ ទើបចាប់ពួកយើង ដូច្នេះហើយ កាលនឹងសួរក្តាម ទើបពោលគាថាទី ៣ ថា*

**ន វាយសំ នោ បន កណ្ហាសប្បំ, ឃាសត្ថិកោ កក្កដកោ អទេយ្យ;**
**បុច្ឆាមិ តំ អាយតចក្ខុនេត្ត, អថ កិស្ស ហេតុម្ហ ឧភោ គហីតា។**

*ចំណែកខាងក្តាម ជាសត្វត្រូវការ ដោយចំណី មិនគួរចាប់ក្អែក មិនគួរចាប់ពស់ទេ ម្នាលអ្នកមានភ្នែកលៀន ខ្ញុំសូមសួរអ្នក ហេតុអ្វី ក៏អ្នកមកចាប់យើងទាំងពីរនាក់ ។*

*បណ្តាបទទាំងនោះ បទថា* **ឃាសត្ថិកោ** *សេចក្តីថា អ្នកមានសេចក្តីត្រូវការអាហារ គប្បីប្រកប* **នអក្សរ** *ក្នុងបទថា* **អទេយ្យ** *អធិប្បាយថា មិនចាប់ ។*

*ក្តាមស្តាប់ពាក្យនោះហើយ កាលពោលហេតុនៃការចាប់ ទើបពោល ២ គាថា ថា*

**យំ បុរិសោ មម អត្ថកាមោ, យោ មំ គហេត្វាន ឧទកាយ នេតិ;**
**តស្មិំ មតេ ទុក្ខមនប្បកំ មេ, អហញ្ច ឯសោ ច ឧភោ ន ហោម។**

*បុរសនេះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ អ្នកណា ចាប់ខ្ញុំនាំទៅក្នុងទឹក កាលបើអ្នកនោះស្លាប់ ខ្ញុំ (នឹងមាន) សេចក្តីទុក្ខច្រើន (ព្រោះ) ខ្ញុំនឹងបុរសនេះ ទាំងពីរនាក់នឹងមិននៅជាមួយគ្នា ។*

**មមញ្ច ទិស្វាន បវទ្ធកាយំ, សព្វោ ជនោ ហឹំសិតុមេវ មិច្ឆេ;**
**សាទុញ្ច ថូលញ្ច មុទុញ្ច មំសំ, កាកាបិ មំ ទិស្វ វិហេឋយេយ្យុំ។**

*ឯអ្នកផងឃើញខ្ញុំមានកាយចម្រើន (ធំ) គប្បីប្រាថ្នា ដើម្បីបៀតបៀនតែប៉ុណ្ណោះ សូម្បីពួកក្អែកបានឃើញខ្ញុំ មានសាច់ឆ្ងាញ់ ក្រាស់ ទន់ ក៏គប្បីបៀតបៀនដែរ ។*

*បណ្ដាបទទាំងនោះ បទថា* **អយំ** *សេចក្ដីថា សម្ដែងដល់ព្រះពោធិសត្វ ។ បទថា* **អត្ថកាមោ** *សេចក្ដីថា អ្នកប្រាថ្នាប្រយោជន៍ ។ បទថា* **ឧកាយ នេតិ** *សេចក្ដីថា អ្នកណាស្រឡាញ់ខ្ញុំ ចាប់ខ្ញុំដោយឧត្តរិសាដក ហើយនាំទៅកាន់ទឹក ឲ្យខ្ញុំដល់អន្ទង់ដែលជាលំនៅរបស់ខ្លួន ។ បទថា* **តស្មិំ មតេ** *សេចក្ដីថា បើអ្នកនោះនឹងស្លាប់ក្នុងទីនេះ ក្ដាមសម្ដែងថា សេចក្ដីទុក្ខតាមផ្លូវកាយ និងតាមផ្លូវចិត្តដ៏ធំ កើតដល់ខ្ញុំក្នុងកាលដែលអ្នកនោះស្លាប់ហើយ ។ បទថា* **ឧភោ ន ហោម** *សេចក្ដីថា សូម្បីយើងទាំងពីរ នឹងមិនបាននៅជាមួយគ្នា ។ បទថា* **មមញ្ច ទិស្វាន** *គាថានេះមានសេចក្ដីអធិប្បាយថា ហេតុនេះ ឬហេតុដទៃក៏ដោយចុះ ជនទាំងពួងបានឃើញខ្ញុំដែលអនាថា មិនមានបច្ច័យ មានរាងកាយធំធាត់ នឹងសម្លាប់ខ្ញុំដោយគិតថា សាច់របស់ក្ដាមនេះ ផ្អែមឆ្ងាញ់ ថ្លោស ទន់ ដូច្នេះហើយ ជនទាំងនោះគប្បីប្រាថ្នាសម្លាប់ខ្ញុំ មិនមែនជនជាមនុស្សប៉ុណ្ណោះទេ សូម្បីក្អែកទាំងឡាយដែលជាសត្វតិរច្ឆានឃើញខ្ញុំហើយ នឹងបៀតបៀនខ្ញុំ នឹងឲ្យខ្ញុំមានសេចក្ដីលំបាក នឹងសម្លាប់ខ្ញុំ ។*

*ពស់ស្ដាប់ពាក្យនោះហើយ គិតថា យើងនឹងបញ្ឆោតក្ដាមនេះដោយឧបាយមួយ ហើយឲ្យលែងក្អែក និងខ្លួន ។ លំដាប់នោះ ពស់ប្រាថ្នានឹងបញ្ឆោតក្ដាម ទើបពោលគាថាទី ៦ ថា*

**សចេតស្ស ហេតុម្ហ ឧភោ គហីតា, ឧដ្ឋាតុ ពោសោ វិសមាវមាមិ;**
**មមញ្ច កាកញ្ច បមុញ្ច ខិប្បំ, បុរេ វិសំ គាឡ្ហមុបេតិ មច្ចំ។**

***បើអ្នកចាប់យើងទាំងពីរនាក់ ព្រោះហេតុតែបុរសនោះ បុរសចូរក្រោកឡើង ខ្ញុំនឹងស្រូបយកពិសចេញ អ្នកចូរលែងខ្ញុំ និងក្អែកឲ្យឆាប់ ព្រោះកាលពីដើម ពិសដ៏ក្លៀវក្លាជ្រាបចូលក្នុងសត្វ ។***

*បណ្ដាបទទាំងនោះ បទថា* **សចេតស្ស ហេតុ** *សេចក្ដីថា ប្រសិន ដោយហេតុនោះ។ បទថា* **ឧដ្ឋាតុ** *សេចក្ដីថា ចូរជាអ្នកប្រាសចាកពិស ។ បទថា* **វិសមាវមាមិ** *សេចក្ដីថា ខ្ញុំនឹង*

ស្រូបពិសរបស់ព្រាហ្មណ៍នោះ នឹងធ្វើព្រាហ្មណ៍នោះឲ្យជាបុគ្គលមិនមានពិស ។ បទថា **បុរេ វិសំ គាឡ្ហមុបេតិ មច្ចំ** សេចក្តីថា ពិសដែលខ្ញុំមិនទាន់ស្រូប នឹងជាពិសដ៏មានកម្លាំងខ្លាំង នឹងចូលក្នុងបុរសនេះ ពិសនោះមិនទាន់ចូលទៅដរាបណា អ្នកចូរលែងយើងទាំងពីរឲ្យធាប់ដរាបនោះ ។

ក្តាមស្តាប់ពាក្យនោះហើយ គិតថា ពស់ឲ្យយើងលែងជនទាំងពីរដោយឧបាយមួយ ហើយជាអ្នកប្រាថ្នានឹងរត់ទៅ វាមិនដឹងនូវយើងដែលជាអ្នកឈ្លាសក្នុងឧបាយ ឥឡូវនេះ យើងអាចឲ្យពស់លូនទៅ ដោយធ្វើការបន្ធូរតង្កៀបយ៉ាងនេះ តែយើងនឹងមិនលែងក្អែកឡើយ គិតដូច្នេះហើយ ក៏ពោលគាថាទី ៧ ថា

**សប្បំ បមោក្ខាមិ ន តាវ កាកំ, បដិពន្ធកោ ហោហិតិ តាវ កាកោ;**
**បុរិសញ្ច ទិស្វាន សុខឹ អរោគំ, កាកំ បមោក្ខាមិ យថេវ សប្បំ។**

***អញលែងពស់ តែមិនលែងក្អែកទេ ព្រោះថា ក្អែកទុកជាអ្នកជានាសិន អញលុះឃើញនូវបុរសមានសេចក្តីសុខ មិនមានរោគ ទើបលែងក្អែក ដូចយ៉ាងពស់ដែរ ។***

បណ្តាបទទាំងនោះ បទថា **បដិពន្ធកោ** បានដល់ អ្នកជានា ។ បទថា **យថេវ សប្បំ** សេចក្តីថា ខ្ញុំលែងពស់ឲ្យចម្រើនយ៉ាងណា ខ្ញុំនឹងដោះលែងក្អែកយ៉ាងនោះដែរ អ្នកចូរបឺតពិសចេញពីសរីរៈព្រាហ្មណ៍នេះឲ្យអស់ ដោយរហ័ស ។

ក្តាមពោលយ៉ាងនេះហើយ ក៏ធ្វើការបន្ធូរតង្កៀប ដើម្បីឲ្យពស់ស្រួលលូនទៅ ។ ពស់បានបឺតពិស ហើយធ្វើសរីរៈរបស់ព្រះមហាសត្វឲ្យអស់ពិស ។ ព្រះពោធិសត្វមិនមានសេចក្តីទុក្ខ ក្រោកឡើង តាំងនៅដោយពណ៌ជាប្រក្រតី ។ ក្តាមគិតថា បើជនទាំងពីរនេះនឹងមិនមានរោគ (ផុតចាកភ័យ) ឈ្មោះថាសេចក្តីចម្រើននឹងមិនមានដល់សម្លាញ់របស់យើង យើងនឹងឲ្យពួកវាវិនាស ដូច្នេះហើយ ក្តាមក៏កៀបក្បាលរបស់សត្វទាំងពីរដោយតង្កៀប ហាក់ដូចជាយកឈើច្រត់កៀបត្របកផ្កាឧប្បល ហើយញាំងក្អែកនិងពស់ឲ្យអស់ជីវិតទៅ ។ ចំណែក

ក្អែកញីក៏បានហើរចេញអំពីដើមត្នោតនោះ ។ ព្រះពោធិសត្វយកឈើរុំសរីរៈពស់ រួចនាំទៅបោលក្នុងគុម្ពព្រៃ ។ លោកចាប់ក្ដាមមាសលែងក្នុងអន្លង់ មុជទឹកហើយ ទើបទៅកាន់សាលិន្ទិយគ្រាមវិញ ។ ចាប់ពីពេលនោះមក សេចក្ដីស្និទ្ធស្នាលដ៏ធំ បានកើតមាន មួយអន្លើដោយក្ដាមនោះ ។

ព្រះសាស្ដាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលនឹងប្រជុំជាតក ព្រះអង្គទើបត្រាស់ឱសានគាថា ថា

**កាកោ តទា ទេវទត្តោ អហោសិ,**
**មារោ បន កណ្ហសប្បោ អហោសិ;**
**អានន្ទោ កក្កដកោ អហោសិ,**
**អហំ តទា ព្រាហ្មណោ ហោមិ សត្ថា។**

***ក្អែកក្នុងកាលណោះ បានមកជាទេវទត្ត ចំណែកខាងពស់វែក បានមកជាមារ ក្ដាមបានមកជាអានន្ទដ៏ចម្រើន ព្រាហ្មណ៍ក្នុងកាលណោះ បានមកជាតថាគត ជាសាស្ដា ។***

ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ជនទាំងឡាយជាច្រើន បានសម្រេចជាសោតាបន្នជាដើម ។ ចំណែកកាកី (ក្អែកញី) ដែលមិនបានពោលក្នុងគាថានោះ បានមកជានាងចិញ្ចមាណវិកា ។

ចប់ សុវណ្ណកក្កដកជាតក ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឆក្កនិបាត ខរបុត្តវគ្គ បិដកលេខ ៥៩ ទំព័រ ៥៨)

ថ្ងៃអង្គារ ៣ កើត ខែវិសាខ ឆ្នាំច សំរឹទ្ធិស័ក ច.ល. ១៣៨០

ថ្ងៃទី ១៧ ខែមេសា ព.ស. ២៥៦១ គ.ស.២០១៨

ដោយខេមរ អភិធម្មាវតារ